# សេចក្តីថ្លែងការរួមរវាងក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# និង អង្គការសុខភាពពិភពលោក

អង្គការសុខភាពពិភពលោកប្រកាសដំឡើងការរីករាលដាលជាសកលនៃជំងឺផ្តាសាយ **A(H1N1)**ទៅដំណាក់កាលទី ៦។

មិនទាន់មានការបញ្ជាក់ថាមានករណី នៃជំងឺផ្តាសាយ **A(H1N1)**នៅក្នុងប្រទេសកម្ពុជានៅឡើយទេ

ក្រសួងសុខាភិបាល, ភ្នំពេញ, ថ្ងៃសុក្រ ទី ១២ ខែ មិថុនា ម៉ោង ១១ ព្រឹក។

យោងតាមសេចក្តីប្រកាសដោយអង្គការសុខភាពពិភពលោកនៅថ្ងៃនេះ ក្រសួងសុខាភិបាលសូមជំរាបជូនដំណឹងដល់សារធារណៈជន អោយបានជ្រាបថា មេរោគផ្តាសាយថ្មីប្រភេទ **A(H1N1)** ឥឡូវនេះកំពុងរីករាលដាលជាលក្ខណៈអន្តរជាតិ និងកំពុងតែបង្កអោយកើតជំងឺនៅតំបន់ផ្សេងៗលើសកលលោក។

នៅក្នុងពេលបច្ចុប្បន្ននេះ អង្គការសុខភាពពិភពលោកបានកំណត់ភាពធ្ងន់ធ្ងរនៃការផ្ទុះជំងឺផ្តាសាយ **A(H1N1)** ថាមានកំរិតមធ្យម។ នៅក្នុងប្រទេសដែលមានករណីជំងឺផ្តាសាយនេះភាគច្រើននៃអ្នកជំងឺបានជាសះស្បើយដោយមិនចាំបាច់សំរាកពេទ្យ ឬ ទទួលការថែទាំវេជ្ជសាស្ត្រឡើយ។ អ្នកជំងឺដែលធ្ងន់ធ្ងរ ឬ ស្លាប់មានចំនួនប្រហាក់ប្រហែលទៅនឹង ជំងឺផ្តាសាយតាមរដូវកាល។ លក្ខណៈនៃអ្នកជំងឺធ្ងន់ធ្ងរ ឬ ស្លាប់នាពេលបច្ចុប្បន្ន ភាគច្រើនកើតចំពោះមនុស្សវ័យជំទង់ ដោយរួមទាំងអ្នកដែលមានសុខភាពល្អពីមុនមក និងអ្នកដែលមានជំងឺប្រចាំកាយ ឬ មានផ្ទៃពោះ។

រហូតដល់ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៩ មិនទាន់មានករណី ជំងឺផ្តាសាយ **A(H1N1)** ក្នុងប្រទេសកម្ពុជាយើងនៅ ឡើយទេ។ ដោយផ្អែកទៅលើការបន្តរីករាលដាលនៃមេរោគជាលក្ខណៈអន្តរជាតិ ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជានឹងបន្តពង្រឹងការអនុវត្តន៏ផែនការជាតិឆ្លើយតបនឹងការរាតត្បាតជាសកលនៃជំងឺផ្តាសាយ និងកំពុងរៀបចំយ៉ាងសកម្ម នូវគោលការណ៏ណែនាំសំរាប់បុគ្គលិកសុខាភិបាល ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក។

មេរោគផ្តាសាយ **A(H1N1)** គឺជាមេរោគថ្មីមួយ ហើយក៏នៅមានពត៌មានជាច្រើនដែលយើងមិនទាន់បានដឹង។ ដោយសារស្ថានការណ៏អាចមានការវិវត្តន៏ប្រែប្រួល ក្រសួងសុខាភិបាលនឹងបន្តជូនដំណឹងដល់សារធារណៈជនពីការវិវត្តន៏ប្រែប្រួលតាមរយៈ គេហទំព័រ **www.cdcmoh.gov.kh** និងសេចក្តីប្រកាសតាមរយៈសារពត៌មាន។

ក្រសួងសុខាភិបាលកំពុងធ្វើការ យ៉ាងជិតស្និតជាមួយ គណកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងដៃគូរ អភិវឌ្ឍន៏ ដើម្បីធានាអោយបាននូវកិច្ចសហប្រតិបត្តិការដ៏មានប្រសិទ្ធភាពខ្ពស់។

ដើម្បីការពារខ្លួនឯង និងអ្នកដ៏ទៃ កុំអោយឆ្លងជំងឺផ្តាសាយ **A(H1N1)** ក្រសួងសុខាភិបាល សូមផ្តល់ដំបូន្មានដល់សាធារណៈជនអោយនៅតែបន្តអនុវត្តន៏អនាម័យផ្ទាល់ខ្លួនស្អាតជានិច្ច ជាពិសេសគឺ :

- ខ្ទប់មាត់ និងច្រមុះ ដោយក្រដាសជូតមាត់ពេលក្អក និងកណ្តាស់
- លាងដៃ ទៀងទាត់ជាមួយសាប៊ូ (ជាពិសេសបន្ទាប់ពីក្អក និងកណ្តាស់ និងមុនពេលបរិភោគអាហារ)
- សូមកុំខាក ស្តោះនៅទីសាធារណៈ

អ្នកទាំងឡាយណា ដែលមានសញ្ញាក្តៅខ្លួនលើសពី ៣៨ អង្សាសេ គួរនៅផ្ទះ, ចៀសវាងទីកន្លែងមានមនុស្សច្រើន កុះករ និងទំនាក់ទំនងលេខទូរសព្ទ័សំរាប់ជំងឺផ្តាសាយនៃក្រសួងសុខាភិបាលដែលមានលេខ: **០១២ ៤៨៨ ៩៨១ ឬ ០៨៩ ៦៦៩ ៥៦៧**។

ក្នុងពេលបច្ចុប្បន្ននេះ មិនទាន់មានវ៉ាក់សាំងការពារជំងឺផ្តាសាយថ្មី **A(H1N1)** នេះនៅឡើយទេ និងអ្នកជំងឺភាគច្រើនក៏ពុំចាំបាច់ត្រូវការថ្នាំប្រឆាំងនឹងវីរុសដែរ។

ការព្យាបាលរួមមាន ពិសារវត្ថុរាវ អោយបានច្រើន, សំរាក និងលេបថ្នាំប៉ារ៉ាសេតាមុល។ អ្នកទាំងឡាយណាដែលមានបញ្ហាផ្លូវដង្ហើម គួរតែរាយការណ៏ទៅមណ្ឌលសុខភាព ដែលនៅជិតបំផុតដើម្បីទទួលបាននូវដំបូន្មានបន្ថែម។

••••••••••••••••••••••••••••••••••••••••••••••••••••••••••••••

សំរាប់ ពតិមានបន្ថែមសូមទំនាក់ទំនង:

**ក្រសួងសុខាភិបាល**

លោកវេជ្ជបណ្ឌិត សុខ ទូច ទូរសព្ទ័ ៨៥៥ ១២ ៨៥៦ ៨៤៨

លោកវេជ្ជបណ្ឌិត លី សូវ៉ាន់ ទូរសព្ទ័ ៨៥៥ ១២ ៨២៥ ៤២៤

**អង្គការសុខភាពពិភពលោក**

លោកវេជ្ជបណ្ឌិត ម៉ៃឃើល អូលែរី ទូរសព្ទ័ ៨៥៥ ២៣ ២១៦ ៦១០